ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៦១ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការកែសម្រួលការិយាល័យមួយចំនួន ក្រោមឱវាទនាយកដ្ឋានថវិកានីយកម្ម និង នាយកដ្ឋានហិរញ្ញកិច្ច នៃអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ ប្រកាសលេខ ១៥០០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការមួយ.-**

ប្រការទាំងឡាយ នៃជំពូកទី៤ ស្តីពីនាយកដ្ឋានថវិកានីយកម្ម និងជំពូកទី៥ ស្តីពីនាយកដ្ឋានហិរញ្ញកិច្ច នៃប្រកាសលេខ ១៥០០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួល ដូចតទៅ÷

### ជំពូកទី៤
### នាយកដ្ឋានថវិកានីយកម្ម

**ប្រការ១៩ ថ្មី.-**

ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម, និង ក្រសួងរ៉ែនិងថាមពល។

**ប្រការ២០ ថ្មី.-**

ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, និង ក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

### ជំពូកទី៥
### នាយកដ្ឋានហិរញ្ញកិច្ច

**ប្រការ២៩ ថ្មី.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម, និង ក្រសួងរ៉ែនិងថាមពល។

**ប្រការ៣០ ថ្មី.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, និង ក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

**ប្រការពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការបី.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៦

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ